I 03033

ប្រវត្តិរូប សមមិត្ត: បុទ្ធិ

ខែ 12.76.

នៅសាលាគរុវិជ្ជា

ក្នុងវគ្គសាលាគរុវិជ្ជា យើងខ្ញុំទាក់ទងជាមួយសិស្ស-សាស្ត្រា និង អនុរក្ស ។

១- ការទាក់ទងជាមួយសិស្សដូចគ្នា ៖

1- នៅថ្នាក់ទី៦ និងទី៥ យើងខ្ញុំរៀនជាមួយក្មួយ អ ស៊ីនស៊ុកចាញ់ ឈ្មោះ ស៊ីនសុវណ្ណ ។ យើងខ្ញុំមានសមាណចិត្តលើវា និងលើ អ.ស៊ីនស៊ុំ ចាញ់ នៅពេលនោះ ចាវាជាអ្នកប្រឆាំងស្តេច ប្រឆាំងនិងបារាំង ។ យើងខ្ញុំទាក់ទងជាសិស្សថ្នាក់ជាមួយគ្នា ។ បញ្ហានយោបាយ យើងខ្ញុំមិនដែលនិយាយជាមួយវាទេ ពីព្រោះមិនយល់អ្វី ។ យើងខ្ញុំមានជំរុញវា ឲ្យខំរៀន ។

2. អ ចាប់ ដា ក៏រៀនជាមួយ យើងខ្ញុំចាប់ពីថ្នាក់ទី៦ដែរ ។ យើងខ្ញុំទាក់ទងនិងវា ពីថ្នាក់ទី៥ ម្យ៉ាងដោយលេងកីឡាដូចគ្នា ម្យ៉ាងទៀតដោយស្នើស្លូត យុត្តិធម៌ ជាមួយគ្នា ។ ក្រោយមកបែកគ្នា វានៅស្មើស្លូតយុត្តិធម៌ យើងខ្ញុំមកកាន់ស្លូត ភាវរ៉ូណា ជាមួយ សាវ៉ាត់ស៊ុ និង ស៊ីវ វ៉ា ។ មូលហេតុគឺរំសាយបុណ្យសក្តិ ម៉ុរមាត ។ ពេលនោះ យោលពីគ្នាមួយរយៈ ចំណែកដោយលេងកីឡា និងរៀនថ្នាក់ជាមួយគ្នា ក៏ជិតគ្នាវិញ ។ ពេលយើងខ្ញុំចេញដំណើរទៅឆេកូស្លូវ៉ាគី វាបានជូនដំណើរយើងខ្ញុំ ។

បញ្ហាដែលវាធ្លាប់បាននិយាយប្រាប់យើងខ្ញុំ គឺ៖

ក- ប្រាក់ដែលទិញសៀវភៅដាក់បណ្ណាល័យសិស្ស វាបានទៅសុំពី ឈ្មុង ជា ស៊ួង អាស៊ី ។

ខ- ក្រោយពីសមាជជាតិ ដែលវាបានស្តាប់ តាវ៉ា ស៊ំពីបញ្ហាខ្មែរកម្ពុជាក្រោម គិញ អ យៀម តាមវាស្គាល់ វាជុះពីតាក់ស៊ីគេចដំនង ។

គ- ពេលវិស្សមកាល មានឃោសនាបោះឆ្នោត វាដើរតាមពួក គណៈបក្ស ខ្មែរ ឃោសនា ។

ឃ- វាបាននិយាយប្រាប់យើងខ្ញុំ អំពីរឿងវិទ្យុកក្កោក លោកគ្រូ ឯកវ៉ាស៊ុន នៅពេលគេចាប់ គួរឲ្យអាណិតណាស់ ។ វាជិតស្និទ្ធនឹង លោកគ្រូ ឯកវ៉ាស៊ុន ហើយធ្លាប់រត់ទៅផ្ទះគាត់ ។

ង- ក្រៅពីនេះ មានបញ្ហាស្នេហារបស់វា ។

3. ស កាពុន រៀនជំនាន់យើងខ្ញុំ យើងខ្ញុំបានទាក់ទងជាមួយ មួយរយៈ ពេលដែលយើងខ្ញុំធ្វើយុវជនរាជសង្គមនិយម ។ សកាពុន នេះជាអ្នកធ្លាប់នៅភ្នំដងរែក បាននិយាយប្រាប់យើងខ្ញុំ អំពីជីវិត នៅភ្នំដងរែក ។

4- អ៊ុំ ណយ រៀនជំនាន់មុនយើងខ្ញុំ ។ ធ្លាប់ធ្វើស្តុក យុត្តិធម៌ជាមួយ គ្នា ស្រុកមកដល់ពេលយើងខ្ញុំ ចេញមកធ្វើស្តុកភវ្វកា ។

5- ណាវ៉ាត់ស៊ុន រៀនជំនាន់មុនយើងខ្ញុំ ។ យើងខ្ញុំធ្លាប់ធ្វើស្តុក យុត្តិធម៌ និងភវ្វកា ជាមួយ ។ នៅឆ្នាំ 1965 យើងខ្ញុំទៅស្រុកបារាំង ជួបនឹង ណាវ៉ាត់ស៊ុន នេះនៅផ្ទះខ្មែរ តែមិនទាក់ទាក់នឹងយើងខ្ញុំ

6- អេម៉ែន ម៉ាកុត រៀនជំនាន់មុនយើងខ្ញុំ ធ្លាប់ធ្វើការជាមួយ គ្នាក្នុងសភាសិស្ស ។ នៅពេលដែលយើងខ្ញុំទៅស្រុកបារាំងឆ្នាំ 1965 វាជួបនឹងយើងខ្ញុំ ហើយបបួលយើងខ្ញុំទៅលេងក្រៅប៉ារីស ។ ក្រោយ មកវាមកលេងបងវា ឈ្មោះ ខម៉ែន ស៊ុំដាវ ធ្វើការនៅល្អូនឡូត នៅប្រាគ យើងខ្ញុំបាន ជូនវាដើរលេង ។

7- ជេង ម៉ុយ រៀនក្រោយយើងខ្ញុំមួយជំនាន់ យើងខ្ញុំជិតស្និទ្ធ លេងកីឡា និងដើរលេងជាមួយគ្នា ។

8- រស់ ពិណា ជាមិត្តជិតស្និទ្ធ រស់នៅបន្ទប់ជាមួយគ្នា ។ រស់ពិណា ធ្លាប់ទាក់ទងជាមួយចាងហ្វាងកាសែត "ឯកភាព" ពេលដែលបង ឈិន សយ ត្រូវចាប់ខ្លួន ។ នៅពេលរស់ពិណា ទៅធ្វើការនៅស្រុកជ

យើងខ្ញុំ ក៏បានទាក់ទងជាមួយតាមសំបុត្រ ។

៩- ស៊ីវ វ៉ា ជាមិត្តជិតស្និទ្ធ រស់នៅបន្ទប់ជាមួយគ្នា និងធ្វើស្កុតជាមួយគ្នា ។ ពេល ស៊ីវ វ៉ា ទៅធ្វើកម្មសិក្សានៅអង្ស៊ីម៉ង់ ខាងកើត ក៏បានមកលេងនិងយើងខ្ញុំនៅក្រាគ្គ ។

10- បាន យ៉ាន រៀនជំនាន់ជាមួយយើងខ្ញុំ ។ យើងខ្ញុំជិតស្និទ្ធក្នុងការលេងកីឡា ។

11- ខៀវ ម៉ម ទុំ ចាប់ស្គាល់ពីថ្នាក់ទី2 ។ យើងខ្ញុំជិតស្និទ្ធក្នុងការលេងកីឡា ។

12- ប៊ី បេង ហេង ធ្វើស្កុតជាមួយគ្នា និងរៀននៅថ្នាក់គណិតសាស្ត្រ ធ្វើស៊ុក គីមី ជាមួយគ្នា ។

13- ឡាច វីរៈ ជុង ចាប់ស្គាល់ពីថ្នាក់ទី2 ធ្លាប់លេងល្បែងជាមួយគ្នា ពេលរៀននៅថ្នាក់ បញ្ចប់មធ្យមសិក្សា ។

14- ជា អេង ស៊ុង ធ្លាប់លេងល្បែងជាមួយគ្នា ហើយបានរួមការប្រឆាំង និង អំពើអយុត្តិធម៌ របស់ អ[illegible] វ៉ាន់ លាក់ ដែលជាឪពុកយើងខ្ញុំ ទាំងអស់គ្នា ដែលរៀន នៅថ្នាក់បញ្ចប់មធ្យមសិក្សា មករស់នៅវិទ្យាស្ថាន ជាតិគរុកោសល្យ ពាងត្លាង ហើយដើរទៅរៀននៅវិទ្យាល័យស៊ីសុវត្ថិ

15- ង មិត្តដូចជា អ៊ុំ លឿន ហង់ ដួន ហ៊ុំ ទ្រិន យើងខ្ញុំគ្រាន់តែ ស្គាល់រាក់រាក់ រុះរាយជាមួយគ្នាជាធម្មតា ។

៧- <u>ការទាក់ទងជាមួយសាស្ត្រាចារ្យ</u>

1- ពាងកីឡា យើងខ្ញុំជិតស្និទ្ធ និងញ៉ុច លោកគ្រូ ស៊ឹម កាម៉ល សៀងដុះ ជួយរៀបចំសម្ភារៈកីឡាគាត់ ។

2- ជាមួយអនុរក្សាជាច់ៗ ដូចជា គឹម តាំង - តា ទូច យើងខ្ញុំ ជិតស្និទ្ធ ធម្មតា ។

ក្នុងការទាក់ទង គឺក្នុងគោលបំណងមិត្តភាព ។ ជាពិសេស អារម្មណ៍ គឺ អនុជន ដូចគ្នា មានចំណូលចិត្តដូចគ្នា ឬ មានគំនិត

សកម្មភាពនៅគរុវិជ្ជា

ពេលជាប់មធ្យមសិក្សាបត្រហើយ យើងខ្ញុំចង់ចេញទៅរៀនបរទេស យើងខ្ញុំបាន ទៅ ស្នើសុំអាហារូបករណ៍ទៅរៀន ៖

ក- ទៅអាមេរិក តែគេថាជាអ្នកមាន យើងខ្ញុំក៏មិនទៅ ។

ខ- ទៅសាលាណាវ៉ាល់ នៅស្រុកបារាំង ។ យើងខ្ញុំបានទៅរៀនខាង ពេទ្យ ឬ ធ្លាប់សមុទ្រ តែគ្មាន យើងខ្ញុំមិនព្រមទៅខាងការទ័ព ។ ពេលនោះ យើងខ្ញុំមានគោលបំណងចង់ធ្វើពេទ្យ ឬ ធ្វើបាល់ទាត់ ក៏ពាក់ព័ន្ធ ។

គ- ធ្លាប់ចូល មើលសៀវភៅក្នុងបណ្ណាល័យ អាមេរិកក្បែរ វិទ្យាល័យស៊ីសុវត្ថិ ។

ឃ- បានទៅរៀន សរសេរសៀវភៅ ជាថ្នាក់មួយមានគ្នាច្រើន ជាមួយអាបង់ដុន ឈាក់ ក្នុងរយៈពេលខ្លី ។ ពេលនោះគឺមុនពេលប្រឡង ស្រឡាន សុគន្ធ ប្រែយជាខ្មែរ ។ យើងខ្ញុំបានសរសេរសៀវភៅ ជាកប្រឡង ខ្លះ ជាមួយវេលា តែមិនបានសរសេរ ។

ង- បានស្ដាប់ ហ៊ុន អាយុម និយាយនៅកណ្ដាល លានភាគម្ចាស់ សាលាគរុវិជ្ជា ពេលយប់ យើងខ្ញុំមិនចាំនរណា អ្នកប្រមូលទេ ហើយនិយាយ អំពីបញ្ហាអ្វី ក៏មិនចាំច្បាស់ ។

ច- ធ្វើការបណ្ណាល័យ នៅក្នុងសភាសិស្ស ពេលអ.ថាប ជាធ្វើ ប្រធាន ។

ឆ- ជើរទាក់ទងខ្ញុំ ឲ្យចូលក្រុង តាមលួនទូតប្រទេសសង្គមនិយម ។

ជ- ទោកបាន ឬ ពែនកាលណា មិនស្គាល់ ។

ឈ- ចំពោះសកម្មភាពនេះ ខ្មែរក្រហម យើងខ្ញុំមិនចាំទេ ។

ចូលសាលាសិក្សា

នៅប្រាគ

មុនចូលសាលាសិក្សា ការទាក់ទងរបស់យើងខ្ញុំនឹងពួកបុគ្គលិកស្ថានទូតអាក្សត់ គឺក្នុងគោលបំណងដូរលុយកាក់-ទិញឥវ៉ាន់និងកុំឲ្យពួកនេះចោទប្រកាន់ថាកុម្មុយនិស្ត ។

ក្រោយពេលទៅនៅក្នុងស្ថានទូតចិន ហើយយើងខ្ញុំបានទទួលទូរលេខពីប៉េកាំងតាមរយៈស្ថានទូតចិនថា ឲ្យបើកការិយាល័យពត៌មានមក សកម្មភាពយើងខ្ញុំគឺ ៖

1- ទាក់ទងនិងក្រសួងចេក ពងទាក់ទងជាមួយទូត ស្នើជួលផ្ទះគេ ដើម្បីធ្វើការិយាល័ពត៌មាន ។ តែមិនបានការ គេចេះតែសន្យាពីខែនេះទៅខែនោះ រហូតដល់ពេលដែលយើងខ្ញុំចេញដំណើរមកប៉េកាំង ។

2- ទាក់ទងអង្គការមហាជនចេក យកព្រឹត្តបត្រទៅឲ្យគេ ពន្យល់គេអំពីជ័យជំនះរបស់ប្រជាជនយើង និងការតស៊ូរបស់ប្រជាជនយើង តាមខ្លឹមសារព្រឹត្តបត្រដែលយើងខ្ញុំបានទទួលពីប៉េកាំង ។ ហើយស្នើឲ្យគេជួយដោះស្រាយបញ្ហាផ្ទះ ធ្វើការិយាល័យពត៌មាន ។

3- ទាក់ទងទូតវៀតណាម ។ យើងខ្ញុំទាក់ទងទូតនេះ ពីព្រោះបងមុម បានប្រាប់យើងខ្ញុំថា បើមានបញ្ហាអ្វីឲ្យទាក់ទងទូតវៀតណាមឬទូតចិន ។

យើងខ្ញុំទាក់ទងទូតវៀតណាមក្នុងគោលបំណងចង់ឲ្យគេជួយធ្វើយ៉ាងណាឲ្យបើកការិយាល័យពត៌មានបាន ពីព្រោះគេជាមិត្តជិតស្និទ្ធនិងចេក ។ មិត្តចិននិងចេកមានការលំបាក ។ ឃើញថាពេលនោះយើងខ្ញុំគ្មានគោលជំហរឯករាជម្ចាស់ការ ហើយពឹងផ្អែកលើគេ ។

4- ទាក់ទងនិងទូតអាល់បានី យើងខ្ញុំទាក់ទងក្នុងឱកាស

បុណ្យ ចុះស្រូបជុំជាមួយមិត្តចិន ។

5- គាត់ទទួលជាមួយទូតចិន ។ យើងខ្ញុំរស់នៅក្នុងទូតនោះ ។ ដំណោះ បញ្ហាខ្លះធ្វើការិយាល័យពាក់មាន មិត្តចិន មានមតិថា ជាបញ្ហា នយោបាយ មិនមែនសម្ពុរះទេ ។

6- ពេល មានខ្មែរ យើង តែរហូត ផ្លូវកាត់តាមព្រៃភ្នំ យើងខ្ញុំ បើបានដំណើរតែងតែទៅទទួលនៅវាលយន្តហោះ ហើយ ជួយក្នុង ការដំណើរការនៅព្រៃភ្នំ ។

នៅបេកាំង

ការពាក់ទង របស់យើងខ្ញុំ នៅប៉េកាំងគឺ៖

១- <u>នៅសណ្ឋាគារមិត្តភាព</u> ។

ក- ជាមួយអ្នកមកពីស្រុកខ្មាំង យើងខ្ញុំជៀសជិតជាមួយ អ្នកមកពីសហភាពនិស្សិតខ្មែរ ។

ខ- ជាមួយអ្នក មកពីម៉ូស្គូ យើងខ្ញុំរាក់ទាក់ធម្មតា ។ នៅពេលដែលយើងខ្ញុំត្រូវចាត់ឲ្យទៅស៊ីស៊ី ដំបូងជាឲ្យយើងខ្ញុំទៅជាមួយបេសកកម្ម ហើយ គីមលុងទៀង ជាអនុ ។ ដល់ក្រោយមកជា យើងខ្ញុំជាអនុរបស់ គីម លុងទៀង វិញ ។ មិត្តពីម៉ូស្គូ ព្រោះយើងខ្ញុំឲ្យប្រញាក់ បងភាគលួន ហើយហើយ៉ាងនេះ វិមន កុំឲ្យពោម ពីព្រោះ គីមលុងទៀង កាលនៅម៉ូស្គូ ធ្លាប់ជាទូលរណសិរ្ស ធ្លាប់ចេញវិញ ។ យើងខ្ញុំបានប្រជុំមិត្តពីម៉ូស្គូ ស្នើមកតិ នៅក្នុងបន្ទប់ ឃាក់ ពិសខ្សាយដី ហើយ សំលេះមិនទៅ ។ រួចសូមខ្ញុំមកក្នុងប្រទេសវិញ ។

គ- ជាមួយបងៗ យើងខ្ញុំជិតស្និទ្ធជាមួយ បងភាគលួន និងបងស្អូនមុម ។

ឃ- ជាមួយ ទេព សំអួន សំអុន វ៉ាន់ពីនី និងកុកប្លា ហៀងម៉េង យក់ចាន់ជា វ៉ាន់ញ៉ឹម ដែលជាក្រុម ជាវនគាក យើងខ្ញុំ ទេរាល ។ ស្អូនកាលក់មានទំនាស់ដែរ ក្នុងការប្រជុំជីវភាពនៅក្នុងក្រុមការបរទេស ។

ង- ជាមួយ អន្ទុំណាំង កាលវានៅសណ្ឋាគារមិត្តភាព យើងខ្ញុំប្រុងប្រយ័ត្ន ពីព្រោះឃើញធាតុបោរបោ ប្រឆាំងបដិវត្តរបស់វា ។

ច- ជាមួយវ៉ាន់ សំផន។ ដំបូងវ៉ាន់ សំផន រាក់ទាក់ ជាក់យើងខ្ញុំ យើងខ្ញុំរាក់ទាក់វិញធម្មតា ក្នុងការលេងកីឡា - ធ្វើត្រពាំងបតិ ។

ក្រោយមក ទៅគណៈបក្ស ផែនប៉ុន មានទំនាស់ ។ នៅពេលយើងខ្ញុំទាំងអស់គ្នា ត្រៀមមកប្រទេស វ៉ៃស៊ីន ក៏មកចូលត្រៀមវៃរ ។ កាលយើងខ្ញុំទៅដល់ប៉ៃកាំងក្លាម វ៉ៃស៊ីន ចូលជិតដដឹកស្បៀង អាវុធគ្រឿងសារ ទូកតូច ស្រុកកំណើតយើងខ្ញុំ ។

ង- ជាមួយ កុលប្ច៉ាដី បាំងពូមិក យីមល្ងាច យើងខ្ញុំភាគរួមគ្នាធ្វើការលេងកីឡា ហើយនិងការត្រៀមមកស្រុកជាមួយគ្នា ។

ឋ- ជាមួយ យ៉ាងរុន - អ៊ី ម៉ុងគាក យើងខ្ញុំភាគ់រួមជាអ្នកធ្វើការក្នុងការិយាល័យជាមួយគ្នា ។ យើងខ្ញុំប្រយ័ត្ន យ៉ាងរុនផឹកពោះភាយការណ៍ឲ្យវ៉ាន់ ផែង ។

2- <u>នៅស្លាននូតកម្ពុជាយើង</u> - យើងខ្ញុំភាគ់រួមក្នុងកិច្ចការក្រៀលកាលជំពាន់៣វែកមាស មន កាំលាំងហាក់ ។ ក្រោយមក ទោ៉ពិន ។

3- <u>អ្នកទៅរំលោភ</u> យើងខ្ញុំមិនភាគ់ភាគ់ទេ មានតែ កាច៉ាងមួយរំដិល ថាមានគ្រឿងសារ ហើយមកនៅសណ្ឋាគារមិត្តភាព យើងខ្ញុំនិយាយលេងជាមួយ ។

4- <u>ចំពោះ ពូកខាយ ផែនប៉ុន</u> ជាការៈកិច្ច ។

យើងខ្ញុំភាគ់រួមជាមួយមិត្តចិន :

ក. នៅសណ្ឋាគារមិត្តភាព យើងខ្ញុំមានការទាក់ទងល្អ មិនដែលមានបញ្ហាអ្វីទេ ។

ខ- ទាង ផែនប៉ុន ។ ជាមួយអ្នកដឹកនាំសហព័ន្ធ កីឡាផែនប៉ុន ចិន មានការទាក់ទងល្អ ។ នៅសាលាហ្វឹកហ្វឺន មានបញ្ហាក្នុងការជួរអ្នកហ្វឹកហ្វឺន ដែលមិត្តចិនស្នើរជួរ ហើយកីឡាករមិនចង់ជួរ ។

នៅប៉ៃកាំងក្នុងការទាក់ទង គឺយើងខ្ញុំមាន គោលបំណង ជួញមិត្ត មិនបង្កើតសត្រូវ ។ ជាសតិអារម្មណ៍គឺ

អនុជនជុំពត្ន មានគំនិតជាសិនស៊ីពត្ន ។

នៅហាណូយ

១- អំពីការទាក់ទង

លើបញ្ហានេះ អង្គការបានដឹកនាំជាប់ជានិច្ច យើងខ្ញុំបាន គោរពធ្វើតាម មិនលើស មិនចេញក្រៅទេ ។

1- ជាមួយវៀតណាម ៗ យើងខ្ញុំគ្មានការទាក់ទងទេ ព្រោះ មិនចេះភាសា ។

2- ជាមួយសមូហភាពកម្ពុជា

ក- ជាមួយ មិត្ត ម៉ុង និងក្មួយៗ ដែលនៅពីក្នុងប្រទេស យើងខ្ញុំ មានការទាក់ទងជិតស្និទ្ធ ។

ខ- ជាមួយសមូហភាព ដែលមកពីប៉េកាំង យើងខ្ញុំមានការទាក់ទងក្នុងការបំពេញភារៈកិច្ច និងជិតស្និទ្ធធម្មតា ។

គ- ជាមួយសមូហភាពនៅហាណូយ ៗ តាមការដឹកនាំរបស់អង្គការ យើងខ្ញុំប្រុងប្រយ័ត្ន ។ យើងខ្ញុំជិតជាមួយក្មួយៗ លោកយាយ ស៊ាល និងមិត្ត ធឿន ។ ឯពួក អា ចាន់ ណាំ ធន ស៊ីវ យើងខ្ញុំប្រុងប្រយ័ត្ន ។ ឯអ្នកនៅក្រៅមន្ទីរ ជួបពេលមកធ្វើការនៅមន្ទីរ គ្រាន់តែនិយាយស្តីធម្មតា ។

២- អំពីសកម្មភាព

សកម្មភាព យើងខ្ញុំនៅហាណូយ គឺ នៅលើ សាលា វិទ្យុ ការងារពលកម្ម ។

1- សាលា ៗ ពេលយើងខ្ញុំនៅដល់ មានបញ្ហាក្នុងសាលា ក្រោមការដឹកនាំរបស់អង្គការ ស៊ាល់ យើងខ្ញុំបានខិតខំបំពេញភារៈកិច្ចនេះ ខាងផ្នែកបច្ចេកទេស គឺ បង្រៀន និង គ្រប់គ្រង ។

2- វិទ្យុ ៗ ក្នុងជំនួយខាងបកប្រែ អានឃ្លា និងស្តាប់ ។

៣- ពលកម្មជញ្ជូនមលក្ខ ។ ក្នុងការដាំដំណាំ - ធ្វើអណ្តូងទឹក - ជញ្ជូន
ហន់ ។

សំណាក់កាលបរិវត្តសង្គមនិយម

ផ្នែកសតិអារម្មណ៍ ៖

ក្នុងបញ្ហាកំទេចកម្មសិទ្ធិឯកជន កសាងកម្មសិទ្ធិសមូហភាព-យើងខ្ញុំពេញចិត្តពេញថ្លើម ហើយយល់ថា ជាមូលដ្ឋាននៃការកសាងសង្គមស្មើភាព គ្មានមាន គ្មានក្រ គ្មានមនុស្សជិះជាន់មនុស្ស ដែលជាឧត្តមគតិយើងខ្ញុំ ។ យើងខ្ញុំខិតខំកសាងខ្លួនទៅតាមទិសនេះឲ្យបានជាលជា ខំពង្រឹងគោលជំហរឲ្យឃើញគ្រប់ភារៈកិច្ច ដែលអង្គការប្រគល់ឲ្យ សុទ្ធតែមានកិត្តិយស សុទ្ធតែបំរើអង្គការ បំរើប្រជាជន ។

ការខ្វះខាតរបស់យើងខ្ញុំគឺ ជាប់និងអនុស្សាវរីយ៍ ប្រើប្រាស់ទៅលើរបស់ស្អ ស្លូតត្បិតគ្រប់ខ្លួន - ទុកជាំ "សិងសិង". ទិញនាឡិកា-ទិញវិទ្យុ កាលចេញទៅបរទេសឆ្នាំ75 ពេលខែមករាបានស្មើអ្នកទទួលខុសត្រូវ (សុំយកឃើញក្នុងរៀបដែលទុកនៅប៉េកាំង) - ប្រមូលលុយយកមកប្រើ-ប្រាក់-ស្រូវគ្រប់តាមយន្តហោះ ។ បុគ្គលនិយម មានៈ ប្រចាំក្នុងការងារ ។

ផ្នែកនយោបាយ ៖

យើងខ្ញុំយល់ថា ត្រូវផ្ដាច់ការវណ្ណៈអធន គឺធ្វើអំណាចត្រូវនៅក្នុងកណ្ដាប់ដៃវណ្ណៈកម្មករ-កសិករ សមូហភាព ជាដាច់ខាត តាំងពីក្រោមដល់លើ ។

ចំពោះអ្នកបំរើការចាស់-

យើងខ្ញុំយល់ថា ប្រើប្រាស់លុះត្រា តែមានគោលជំហរវណ្ណៈអធន ពុំនោះទេ អត់ប្រើប្រាស់ ។

ផ្នែកចាត់តាំង

បញ្ហាមិនចាយលុយ យើងខ្ញុំពេញចិត្តពេញថ្លើម និងវិធានការណ៍របស់អង្គការ ហើយយល់ឃើញថា ត្រឹមត្រូវ ។

យើងខ្ញុំរស់នៅមិនងាយលុយស្រួល ។ នៅពេលបំពេញភារៈកិច្ច ត្រូវចាយលុយ យើងខ្ញុំពិបាក គិត-គត់ ហើយខ្វះខាត ។ យើងខ្ញុំ ឃើញថា លុយជា ១ ឧបករណ៍ងាយនឹងផ្លាស់ ។

<u>ពិនិត្យក្នុងការបំពេញភារៈកិច្ច ៦ ខែ នៅប,</u>

មកដល់ប, យើងខ្ញុំទទួលភារៈកិច្ច :

១- <u>ការិយាល័យ</u> : លិខិតឆ្លងដែន ត្រា -ឯកសារ- ទាក់ទងជាមួយមន្ទីរ ស្រង់ប្រវត្តិរូបពួកទូតបរទេស និង ជួយវាយសំបុត្រស្នាម ។

គុណសម្បត្តិ : យើងខ្ញុំបានខិតខំបំពេញភារៈកិច្ចល្អ :

<u>លិខិតឆ្លងដែន</u> : បានកត់ត្រា មុននិងចេញលិខិតឆ្លងដែនឲ្យ ឬ ទទួលយកទុក ឬចេញទិដ្ឋាការឲ្យបរទេស ទៀងទាត់ ។

<u>ត្រា</u> : បានប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ ទុកដាក់ មុនវាយត្រាលើសំបុត្រ ដូចជា បើកផ្លូវ បានសួរទៅមន្ទីរ ឬគាល់អគ្គមន្ទីរ ប្រាប់ឲ្យធ្វើ ។ មួយរយៈកាល ត្រាយកទៅទុកនៅមន្ទីរ ។

<u>ឯកសារ</u> : បានរៀបចំទៅតាមថ្ងៃ តាមស្រុក តាមឯកសារចេញពីកម្ពុជា ឬចូលមកកម្ពុជា ។ ឲ្យស្រួលរក ។ បានប្រុងប្រយ័ត្នក្នុងការទុកឯកសារ ហើយមានការផ្ញើរ៉ឺទៅ ៩ ផ្នែកផ្សេង តាមយកមកវិញ ។

ទាក់ទងជាមួយមន្ទីរ : បានខិតខំសម្រួលការងារក្នុងការរៀបចំទទួលភ្ញៀវ ក្នុងការបញ្ជូនឯកសារ ។

<u>ប្រវត្តិរូបពួកទូតបរទេស</u> : បានធ្វើបញ្ជីស្រង់ឈ្មោះពួកទូត ដែលមកនៅកម្ពុជា ។ បានកត់ឈ្មោះបរទេសដែលចូលមកក្នុងប្រទេសយើង ទៀងទាត់ កាលណាបានទទួលលិខិតឆ្លងដែន ។

<u>សំបុត្រស្នាម</u> : បានខិតខំជួយវាយសំបុត្រ សារជូនពរ ស្នូក្រដា:

ការរិះគត

<u>សាវិតក្នុងវែន</u> : បានតែតក់ មិនបានតាមគិនជំរៅឲ្យដឹងច្បាស់
ជាបរទេសណា ចេញច្បាប់ប៉ុន្មានដែរ ។

<u>ឯកសារ</u> : រៀបមិនទាន់បាន ឲ្យល្អិត ។ ស្រុកខ្មែរមិនទាន់មានការ
ទាក់ទងញឹកញាប់ នៅអឺរ៉ុប នៅឡើយ ។

ទាក់ទងជាមួយមន្ត្រី : ក្រុមមិនរាប់ក្នុងការទទួលភ្ញៀវ ឬ រៀបចំកិច្ចប្រជុំ
ជូនអង្គការ ក្រៅការ ។

ប្រ<u>វត្តិរូបពួកទូតបរទេសនៅកម្ពុជា</u> :

១: ក្រុមប្រវត្តិរូប បុគ្គលិកក្នុងទូតម្នាក់ៗ បានតែតាមសាវិត
ក្នុងវែន ។

២: ក្រុមមិនរាប់ចំនួន មនុស្សក្នុងស្ថានទូតម្នាក់ៗ ។ បានស្គាល់តាម
កិច្ចការ តែមិនដឹងច្បាស់ ។

២- <u>តាមគណៈប្រតិភូ</u> : ការពារ - ជំនួយការ ។

គុណសម្បត្តិ :

<u>ការពារអង្គការ</u> : បានត្រៀមផ្លូវតើ ការពារជិតគត - បាន
ប្រុងប្រយ័ត្នក្នុងការ ពិនិត្យបន្ទប់-របស់ប្រើប្រាស់-ឡានគ្រឿង
ផ្ទុះ - បានប្រយ័ត្នក្នុង ថ្នាំពេទ្យ - ក្នុងការយាមកាម នៅដប៉ុន ។
ត្រៀមការពារក្នុងការធ្វើដំណើរ ពាមក្រៅ ។

<u>ជំនួយការ</u> : បានគិតគូរ រៀបចំសម្ភារៈ សំរាប់ការត្រូវការ
របស់គណៈប្រតិភូ បានរៀបចំឯកសារ ជំនួន រឹការ
ពីសាវិតក្នុងវែន ពីសំបុត្រយន្តហោះ ។ ក្រោយពីការ
ដឹកនាំដំណោះនៅដប៉ុន មក បានគិតគូរ ឲ្យចាត់ដល់លុយ
ដែលជារឿយ លាប ប្រដាប់ដែល យើង ក្នុងការចាយវាយ - ទិញ
សំបុត្រយន្តហោះ ទៅប៉ារីស តាមការចុះថ្លៃ ។

រិះគត :

<u>ការពារអង្គការ</u> : មិនស្គាល់ស្រីទំនៀកលើមិត្ត ស៊ីប ។ គិត

មិនស្អិតក្នុងការត្រូវទៅជាំបន្ទប់ ឬត្រូវទៅ គឺមិនចិត្តគត ។ មានការគ្រូរលុំ - សំភាកក្នុងរៀន ពេលឆ្លើយដំណើរ - តាមដានមិន មុនយកឡើងយន្តហោះ ។

<u>ជំនួយការ</u> : ក្នុងការត្រៀមជំនួន មិនបានល្អ ធ្វើការជាមួយក្មេង នៅមិនបានល្អសរ -(ទៅលេងលុយកាក់កណ្តាលវាល)- មិនបានមានគំនិតខ្លួនបេចទិក ចាំទីតបញ្ជា ។

<u>ចលនាបី</u>

<u>គុណសម្បត្តិ</u> :

យើងខ្ញុំបានចូលរួមទៀងទាត់ក្នុងចលនាសន្សំសំចៃ ។ ក្នុងចលនាទិះទៀនស៊ូយទិះទៀន និងរៀនសូត្រ យើងខ្ញុំបានតាមដានសតិអារម្មណ៍ និងត្រួតពិនិត្យគោលជំហរ ហើយបានរំពង្រឹងគោលជំហរល្អ និងកំចាត់សតិអារម្មណ៍មិនល្អ ។ ក្នុងចលនារៀនសូត្រ បានរៀនវាលម្មុយភាពដង និងបានយកឯកសារចាស់ៗមករៀនពាក់ព័ន្ធឡើងវិញ ។ ក្នុងចលនាពលកម្ម បានចាប់និងពលកម្មសម្ពនិយម. ដោយមានជំនឿថាពលកម្មជួយពង្រឹងគោលជំហរកម្មជីពរបស់អ្នកការ ។

<u>ខ្វះខាត</u> :

<u>សន្សំសំចៃ</u> : ធ្វើៗតាមគេ តាមវេន មិនបានគិតគូរពិចារណាស៊ីជំរៅ. ។

<u>រៀនសូត្រ</u> : ការពាក់ព័ន្ធមិនបានជំរៅ ខ្វះការយកការខ្វះខាតហើយកំទេចវា. ។ នៅសើៗ ។

<u>គោលជំហរសតិអារម្មណ៍</u> : តាមដានឃើញគោលជំហរ សតិអារម្មណ៍ចុះហើយ មិនបានកំទេចវា ទុកឲ្យវាមកលង់រាល់ថ្ងៃ ។

<u>ពលកម្មសម្ពនិយម</u> : ធ្វើប្រយុទ្ធមិនបានក្តៅគគុក នៅមើលគេមើលឯង ប្រៀបធៀប ។

សរុបៈ

ក្នុងរយៈកាលសិក្សា ជីវិតរបស់យើងខ្ញុំ ក្នុងការភាក់ទង គឺពៀនពិត ស្លូតស្លុប ។ ភាក់ទងនិងពួក ដែលក្រោយមកក្បត់ប្រទេសជាតិ ម្នាក់ៗដូចជាពួកអក្បត់ ។ ម្យ៉ាងទៀតពង់ការរស់នៅក៏មិនបានល្អតល្អំ គឺខ្ជះខ្ជាយកាក់ រកស៊ីដាច់មានបាន ។ សីលធម៌ជាបុរសក៏មិនបានល្អតល្អំ ។ ហើយសារគុណអង្គការ យើងខ្ញុំបានវិលមករកខ្លួនវិញ ខ្លួនបដិវត្តកម្ម ។ បានរីករាយណាស់ តាមការណែនាំរបស់អង្គការ ។ ក្នុងដំណាក់កាលបដិវត្តសង្គមនិយមនេះ យើងខ្ញុំមានតែប្តេជ្ញាខំកសាងខ្លួន ដើម្បីតបស្នងសងគុណអង្គការ ដែលបានយកពេលវេលា ដ៏មមាញឹក ខំបំពាក់បំប៉នគោលជំហរ នយោបាយ សតិអារម្មណ៍ ឲ្យយើងខ្ញុំ និងការទំនុកទុកចិត្តរបស់អង្គការ និងដើម្បីតបស្នងសងគុណប្រជាជនកម្ពុជាដែលបានចិញ្ចឹមបីបាច់យើងខ្ញុំ ។ យើងខ្ញុំមានតែប្តេជ្ញាខំបំពេញភារៈកិច្ច ដែលអង្គការប្រគល់មកឲ្យបានដាច់ខាត ប្តេជ្ញាបំបាត់ការខ្វះខាត ដែលមានកន្លងមក ខិតខំកសាងខ្លួនឲ្យបានជាជនបដិវត្តមួយរូប ។

ដកពិសោធន៍លើការភាក់ទងរូបកន្លងមក យើងខ្ញុំមានតែប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ក្នុងការភាក់ទង. មើលគោលជំហរបដិវត្ត មើលវណ្ណៈភាព ។ ហើយមើលឲ្យឃើញការភាក់ទងក៏ជាកម្មសិទ្ធិសមូហភាពដែរ ។

គំរូលេខ ៨ 					សំងាត់ណាស់

ស្ថិតិឯកសារមានក្នុងសំណុំឯកសារ លេខ ~~298~~ ២០៩៨

ល-រ	កម្មវត្ថុឯកសារ	ពីទំព័រ ដល់ទំព័រ	បញ្ជូនឯកសារ
01	[illegible]	01-18	
02	[illegible]	14-28	
03	[illegible]	29-38	
04	[illegible]	39-48	
05	[illegible]	49-58	
06	[illegible]	59 68	
07	[illegible]	69-78	
08	[illegible]	79-88	
09	[illegible]	89-98	
១០	[illegible]		